ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣១-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១៣២ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន០៩ រូប ៣០៥៧

០២-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៣៤ ស្តីពីការតែងតាំងឯកឧត្តម **សុន ឆ័យ** ជាសមាជិកគណៈកម្មការកំណត់អាសនរដ្ឋសភា សម្រាប់នីតិកាលទី ៤ ជំនួសឯកឧត្តម **គឹម ចំនួនសុមិត្រ** ដែលបានលាឈប់ពីមុខតំណែង ៣០៥៩

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

០៤-៤-២០០៧ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន ៣០៦០

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៣

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៤

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៥

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៦

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៧

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៨

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣០៦៩

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣០៧០

០៥-៤-២០០៧ -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៧១

២_សេចក្តីសំរេច

០៥-៤-២០០៧ -សេចក្តីសំរេចលេខ ១៨ សសរ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៧ ៣០៧២

III~ការងារបណ្ដាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

១៩-៣-២០០៧ -ប្រកាសលេខ ០៧៦ ប្រ.ក.សក.ប.ធ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ នាយកដ្ឋាន ផ្លូវថ្នល់ ៣០៧៤

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អាយ អេច ហ្គោលដេន** ៣០៨៥

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេហ្សុង ខ្មែរ អ៊ែត ទើធីសម៉ិន មេឌា អែន ខនស្ត្រាក់សិន** ៣០៨៧

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ីន ទ័កឃីង ត្រាក់ន័រ (ខេមបូឌា)** ៣០៨៩

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ុត (ខេមបូឌា) អ៊ិនធើណេសិនណល គ្រុប** ៣០៩១

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុក នីញ ក្រចេះ អភិវឌ្ឍន៍ កៅស៊ូ** ៣០៩៣

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តៃ អូស រៀល អ៊ីស្ទេត ឌីវេឡុបមេន** ៣០៩៥

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ម៉ី ជេ ខបភើរេសិន** ៣០៩៧

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៦៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដុង ត្វ ក្រចេះ អភិវឌ្ឍន៍ កៅស៊ូ** ៣០៩៩

គ

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធ្វី ខ្មៀន ខូ អិលធីឌី** ៣១០១

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ត្រានីត (ខេមបូឌា) គ្រុប** ៣១០៣

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១៣២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្ដីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ឯក ខែត សុវណ្ណារត្ន អត្តលេខ ០០១៥៧៩

២-វរសេនីយ៍ឯក ម៉ូ គឹមឆេង អត្តលេខ ០០២៧៥១

៣-វរសេនីយ៍ឯក អ៊ុម សុមេធ អត្តលេខ ០០០៥៦២

៤-វរសេនីយ៍ឯក សូ សាម៉េន អត្តលេខ ០០០៥៦៤

៥-វរសេនីយ៍ឯក ប្រ៊ីង ទេង អត្តលេខ ០០០៥៥៧

៦-វរសេនីយ៍ឯក ញៀប សុផាន់ណារ៉ា អត្តលេខ ០០២៤២៦

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៧-វរសេនីយ៍ឯក គី ឡេង អត្តលេខ ០០២២៣៤

៨-វរសេនីយ៍ឯក ហ៊ឹម ស៊ុនណារី អត្តលេខ ០០២៥៦៦

៩-វរសេនីយ៍ឯក ហ៊ឹម ណារិទ្ធ អត្តលេខ ០០៤៥២៤

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរ/ល·០៧០៣·១៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ[illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

44.

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មី ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៧/០៣៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការកំណត់អាសនរដ្ឋសភា សម្រាប់នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **សុន ឆ័យ** ជាសមាជិកគណៈកម្មការកំណត់អាសនរដ្ឋសភា សម្រាប់នីតិកាលទី៤ ជំនួសឯកឧត្តម **គឹម ច័ន្ទសុមិត្រ** ដែលបានលាឈប់ពីមុខតំណែង ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៤.១៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ២០០៧

លេខ ១៥៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ឃ្លោលហ្វេមដាកស៊ីន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១

នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំរេច

មាត្រា១.-

បង្កើត **តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន** (**GOLDFAME PAK SHUN SEZ**) ដែលមានទីតាំងស្ថិតនៅឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ។

មាត្រា២.-

តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន មានទំហំ ប្រាំពីររយហាសិបពាន់ ប្រាំពីររយប៉ែតសិបប្រាំបីម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្រ្តក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

មាត្រា៣.-

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

មាត្រា៤.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ

និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកណ្តាល និងក្រុមហ៊ុន ហ្គោលហ្វេមជាកស៊ីន អេសអ៊ីហ្សិត ខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា
អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តា

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៩ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការផ្ដល់គ្រឿងឥស្សរិយយសជាតិ

១០១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា មានព្រះវិហារ កុដិតំកល់គម្ពីរ ធ្វើផ្លូវចូលទៅវត្ត ០១ខ្សែ ប្រវែង ១.០០០ ម៉ែត្រ ជីកស្រះ នៅវត្តព្រៃបាស្រី ឃុំដែកពក ស្រុកព្រះស្ដេច ខេត្តព្រៃវែង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-លោក	**មិត្ត ការ៉េន**	សប្បុរសជននៅភ្នំពេញ	ថវិកាចំនួន ២៥.០០០ ដុល្លារ
២-ឯកឧត្តម	**ហ៊ី ណារី**	ទីប្រឹក្សា សម្ដេច ជា ស៊ីម	ថវិកាចំនួន ១៥.០០០ ដុល្លារ
៣-ព្រះតេជគុណ	**សំ ធីរះ**	ព្រះចៅអធិការវត្តព្រៃបាស្រី	បច្ច័យចំនួន ១០.០០០ ដុល្លារ

ខ_មេដាយសំរឹទ្ធស្ថាបនាជាតិ :

-លោក	**រេហា ហ៊ឹម**	សប្បុរសជននៅភូមិក្រសាំងជេត ឃុំដែកពក	ថវិកាចំនួន ៣.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ … ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៩០-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៑៑៑

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ អណ្តូងស្នប់ ចំនួន ០៤កន្លែង ជួសជុលផ្លូវថ្នល់ ផ្តល់សំភារៈបរិក្ខារពេទ្យ ជូនពេទ្យបង្អែកស្រុក ឧបត្ថម្ភដល់បុគ្គលិកពេទ្យ និងទូកង នៅក្នុងឃុំកំពង់ឫស្សី ឃុំព្រៃស្រឡិត ឃុំរកា និង ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង ដូចមានរាយ នាមខាងក្រោម ៈ-

១-លោក **ម៉េង ឡេង** អគ្គនាយកក្រុមហ៊ុន ម៉េង ឡេងអ៊ីរ ថវិកាចំនួន ១០.៤២៣ ដុល្លារ

២-លោកវេជ្ជបណ្ឌិត **គង់ សំអុន** អនុប្រធានការិ.សុខាភិបាលស្រុកប្រតិបត្តិពារាំង ថវិកា ចំនួន ១០.១៣០ ដុល្លារ

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជ

រាជរដ្ឋា[illegible]

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ ០១ និងសប្បុរសជន ០២រូប ដែលបានឧបត្ថម្ភថវិកា ជួយសាងសង់ សាលាមត្តេយ្យ ចំនួន០១ខ្នង បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ និងទិញអូប៊ែរ ចំនួន ០១គ្រឿង បំពាក់ដោយបរិក្ខារជួយសង្គ្រោះ ជូនដល់ទីចាត់ការសុខាភិបាល ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-អង្គការ Asian Outreach Cambodia បានឧបត្ថម្ភថវិកា ចំនួន ៦០.០០០ ដុល្លារ

២-លោកស្រី HILDEGARD PELZ សប្បុរសជនសញ្ជាតិ អាល្លឺម៉ង់ បានឧបត្ថម្ភថវិកា ចំនួន ២០.០០០ ដុល្លារ

៣-លោក PATRICK MOONEY សប្បុរសជនសញ្ជាតិ ហូល្លង់ បានឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩៧ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ០៣រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តសុភី ហៅ វត្តកកោះ ស្ថិតក្នុងឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ដូចមានព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ	**រ៉េទ ភុសល**	ចៅអធិការ វត្តសុភី	បច្ច័យចំនួន ៨៣.៣៦៩ ដុល្លារ
២-លោកស្រី	**សាន ទិបុល**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកាចំនួន ៤៥.៣៤៤.១០ ដុល្លារ
៣-ឧបាសិកា	**ហាក់ ពត**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកាចំនួន ១០.៤៧៥.២៥ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩៣ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ជប៉ុន ចំនួន ០៥រូប ដែលបានឧបត្ថម្ភថវិកា ចំនួន ១១១.៩០១.៣០ ដុល្លារអាមេរិក តាមរយៈអង្គការ **FIDR** សំរាប់សាងសង់អគារថ្មី នៅមន្ទីរពេទ្យកុមារជាតិ និងផ្តល់ថវិកាសំរាប់អោយមន្ទីរពេទ្យអនុវត្តការផ្តល់ម្ហូបអាហារជម្ងឺតាមឯកទេស រយៈពេល០៥ឆ្នាំ ដូចមានរាយនាមខាងក្រោម :-

១-Dr.NOBUHIRO IIJIMA	នាយកយុទ្ធនាការ យ៉ាម៉ាហ្សាគី ឡូវលូហ្ ជាម្ចាស់អំណោយ
២-Mr.and Mrs YOKOYAMA	ជាម្ចាស់អំណោយ
៣-Rev.HIROSHI SAKAKIBARA	នាយកមូលនីធិសំរាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ
៤-Mr.YOSHINARI SUMI	Secretary Genaral FIDR
៥-Mr.KOTARO ICHIKAWA	នាយកមូលនីធិសំរាប់ការអភិវឌ្ឍន៍ និង ជំនួយសង្គ្រោះអន្តរជាតិប្រចាំនៅកម្ពុជា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ទោ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាងសំណង់នានា នៅទីបញ្ជាការដ្ឋានយោធភូមិភាគទី២ ដូចមានរាយនាមខាងក្រោម :-

១-វរសេនីយ៍ឯក	**នូ សារ៉ាន់**	នាយរងសេនាធិការយោធភូមិភាគទី២	ថវិកាចំនួន ១០.២០០ ដុល្លារ
២-វរសេនីយ៍ឯក	**ទាំ សំអុល**	នាយរងសេនាធិការយោធភូមិភាគទី២	ថវិកាចំនួន ១០.២០០ ដុល្លារ
៣-វរសេនីយ៍ទោ	**អ៊ាត ម៉ុនរឿន**	មេបញ្ជាការរងតំបន់សឹករងកំពង់ចាម	ថវិកាចំនួន ១០.១០០ ដុល្លារ
៤-វរសេនីយ៍ត្រី	**មាស សុខុម**	នាយរងផ្នែកព្រំដែនយោធភូមិភាគទី២	ថវិកាចំនួន ១០.២០០ ដុល្លារ
៥-វរសេនីយ៍ត្រី	**ស៊ីន សំអឿន**	នាយរងការិយាល័យទី២ យោធភូមិភាគទី២	ថវិកាចំនួន ១០.១០០ ដុល្លារ
៦-វរសេនីយ៍ត្រី	**ខួន សុខុន**	មេបញ្ជាការវរសេនាតូច វិស្វកម្មភូមិភាគទី២	ថវិកាចំនួន ១០.២១០ ដុល្លារ
៧-វរសេនីយ៍ត្រី	**ស ឈាន**	មេបញ្ជាការវរសេនាតូច ការពារព្រំដែនលេខ ២០៣	ថវិកាចំនួន ១០.០៥០ ដុល្លារ
៨-វរសេនីយ៍ត្រី	**ម៉ុល សុធី**	មេបញ្ជាការវរសេនាតូចលេខ២១២ កងពលតូចលេខ២១	ថវិកាចំនួន ១០.១០០ ដុល្លារ
៩-អនុសេនីយ៍ឯក	**សាត ចន្ថា**	មេបញ្ជាការវរសេនាតូច លេខ២១ កំពង់ចាម	ថវិកាចំនួន ១០.១០០ ដុល្លារ
១០-អនុសេនីយ៍ត្រី	**លឹម ម៉ុណ្ណា**	ជ.ការិយាល័យទី២ តំបន់សឹករង កំពង់ចាម	ថវិកាចំនួន ១០.១២០ ដុល្លារ
១១-លោក	**ស៊ិន សម្ភស្ស**	សប្បុរសជន នៅខេត្តកណ្តាល	ថវិកាចំនួន ១៣.៥០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ X+

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៩៥.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **ឃួន សារី** ចៅអធិការវត្តអង្គប្រីយ ដែលបានបរិច្ចាគបច្ច័យ ជួយកសាងសាលារៀន ព្រះវិហារ ផ្លូវលំ និងសមិទ្ធផលផ្សេងៗទៀត នៅវត្តអង្គប្រីយ ក្នុងឃុំសំរោង ស្រុកកំពត ខេត្តកំពត អស់ទឹកប្រាក់ចំនួន ៣៧០.៣៥១,៦៦ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩៦.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

របស់

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពង់ធំ ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការបំរើជាតិ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១-លោកស្រី	**ស្វាយ នាង**	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពង់ធំ
២-លោក	**ស៊ាន ជា**	ប្រធាន បុរីកុមារ ខេត្តកំពង់ធំ

ខ_មេដាយប្រាក់ការងារ :

១-លោកស្រី	**រស់ រេងឡាង**	អនុប្រធានការិយាល័យ សុខុមាលភាពកុមារ ខេត្តកំពង់ធំ
២-លោកស្រី	**ហ៊ុន សារឿន**	អនុប្រធាន បុរីកុមារកំព្រា ខេត្តកំពង់ធំ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការក្រៅរដ្ឋាភិបាល ដែលបានឧបត្ថម្ភថវិកាជួយដល់វិស័យអប់រំ នៅរាជធានីភ្នំពេញ ដូចមានខាងក្រោម :-

១-អង្គការ ROOM TO READ បានជួយសាងសង់បណ្ណាល័យ និងផ្តល់សម្ភារៈបណ្ណាល័យដល់សាលាបឋមសិក្សាភ្នំពេញថ្មី ផ្តល់ម៉ាស៊ីនកុំព្យូទ័រ ដល់អនុវិទ្យាល័យទឹកល្អក់ និងវិទ្យាល័យជ្រោយចង្វារ ព្រមទាំងជួយបង់ថ្លៃភ្លើង រយៈពេល០២ឆ្នាំ និងជួយជួសជុលបន្ទប់ស្តាប់ភាសា នៅវិទ្យាល័យបឹងត្របែក ចំណាយអស់ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ ។

២-អង្គការ CIAI បានជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សាភ្នំពេញថ្មី ចំណាយអស់ទឹកប្រាក់ ចំនួន ២៥.០០០ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤ សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៥/ ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខនស/រកត/០៩៩៥ /៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ១ : ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ មានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សេង សាខន** អនុប្រធានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **លួ រ៉ាម៉ាន** អគ្គលេខាធិការ នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុប្រធាន

៣- ឯកឧត្តម អ៊ឹង គីវុន រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៤- ឯកឧត្តម ម៉ឹន សម រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៦- ឯកឧត្តម សាត សាមី អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក

៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក ឈឹម សុជាតិ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក នេត សាវឿន អគ្គស្នងការរងនគរបាលជាតិ សមាជិក

៩- ឯកឧត្តម កង ហ៊ាង អភិបាលខេត្តកំពង់ស្ពឺ សមាជិក

១០- ឯកឧត្តម ឧត្តមសេនីយ៍ទោ ម៉ឹក ដារ៉ា អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ និងនាយកមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក

១១- លោក គីម សោភ័ណ ចៅក្រម ក្រសួងយុត្តិធម៌ សមាជិក

១២- លោកឧត្តមសេនីយ៍ត្រី ឌួច ណារ៉ុង ស្នងការនគរបាលរាជធានីភ្នំពេញ សមាជិក

១៣- លោកវរៈសេនីយ៍ឯក កែវ ពិសី ស្នងការនគរបាលខេត្តកំពង់ស្ពឺ សមាជិក

១៤- លោក មាស វិរិទ្ធ ប្រធានមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

១៥- លោក ឃុត សុគារុង ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ស្ពឺ សមាជិក

១៦- លោក ដួង ស៊ីនណារ៉ា ប្រធានស្តីទី នាយកដ្ឋានអនុវត្តច្បាប់ សមាជិក

ប្រការ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាខេត្តកំពង់ស្ពឺ សាលាក្រុងភ្នំពេញ និងសាមីខ្លួនមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៧

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : ០.៣៦....ប្រ.ក ស.ក បណ

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមិនា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី..០៧.. ខែមេសា ឆ្នាំ2007

ប្រកាស

ស្តីពី

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋាន ផ្លូវថ្នល់

រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម / ០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក. ចុះថ្ងៃទី ០៣-០៣-១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

សម្រេច

ប្រការ ១ : នាយកដ្ឋានផ្លូវថ្នល់ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានសាធារណការ ហើយមានតួនាទី និងភារកិច្ច ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យលេខ ១៤ អនក្រ.បក.ចុះថ្ងៃទី ០៣-០៣-១៩៩៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន :

- នាយកដ្ឋានផ្លូវថ្នល់ មានបន្ទុកថែទាំគ្រប់គ្រងសមិទ្ធិ និងតាំងបទបញ្ជារាជីវកម្មលើហេដ្ឋារចនាសម្ព័ន្ធជាអាទិ៍ ផ្លូវថ្នល់ ស្ពាន កំពង់ចម្លងរដ្ឋ និង ឯកជន។

តួនាទី ភារកិច្ចរបស់នាយកដ្ឋានផ្លូវថ្នល់ :

ក. រៀបចំកម្មវិធីការងារថែទាំ គ្រប់គ្រងផ្លូវថ្នល់ :

១. គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ផ្លូវថ្នល់ ដីចំណីថ្នល់ :

- តាក់តែងច្បាប់ អនុក្រឹត្យ សារាចរដើម្បីគ្រប់គ្រងផ្លូវថ្នល់ជាអាទិ៍ ការកំណត់ នូវទំងន់ចរាចរប្រើប្រាស់លើផ្លូវថ្នល់ និងស្ពាន អនុសញ្ញានូវការប្រើប្រាស់ផ្លាកសញ្ញា ផ្លូវថ្នល់ សារាចរ ស្តីពី សណ្តាប់ធ្នាប់ការប្រើប្រាស់ផ្លូវថ្នល់ ដីចំណីថ្នល់ សំណង់សិល្បការ្យ បរិក្ខារផ្លូវថ្នល់ជាដើម ។ល។

២. ធ្វើសំរង់ទិន្នន័យ និងប្រើប្រាស់ទិន្នន័យចាំបាច់ដើម្បីយល់ដឹងពីបញ្ហាផ្លូវថ្នល់ :

- រៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវថ្នល់ រួមមានផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ។

- ស្រាវជ្រាវពត៌មានសេដ្ឋកិច្ច សង្គមកិច្ច និងបច្ចេកទេស ដើម្បីលើកទិសដៅកសាងផ្លូវថ្មី ឬ លើកកំរិតផ្លូវដូចជាការបង្កើតតំបន់អភិវឌ្ឍន៍ថ្មីជាដើម ។

៣. សំរង់គ្រប់គ្រងឯកសារគំរោងបច្ចេកទេសថ្នល់ និងពត៌មានទាំងឡាយដែល ពាក់ព័ន្ធនឹងបណ្តាញផ្លូវថ្នល់ :

- ប្រមូល សំរង់ គ្រប់គ្រងឯកសារគំរោងបច្ចេកទេសការងារសាងសង់រួច កំពុងសាងសង់ ឬ បំរុងសាងសង់ទុកជា ឯកសារដើម្បីធ្វើការសិក្សាលើគំរោងថែទាំ និងជួសជុល ។

- ស្រង់ពត៌មាននូវគ្រោះថ្នាក់ចរាចរ តាមផ្លូវថ្នល់នានា ។

៤. រៀបចំថវិកា បែងចែកមធ្យោបាយ តាមដាន និងត្រួតពិនិត្យលើការងារថែទាំផ្លូវថ្នល់ :

- រៀបចំផែនការប្រចាំឆ្នាំ ដោយលើកគំរោង ការស្ថាបនា ការសាងសង់ ការស្តារឡើងវិញ នូវសេចក្តីត្រូវការ ថវិកាសំរាប់ជួសជុល ថែទាំផ្លូវថ្នល់ កំពង់ចម្លង ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ។

៥. ត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ។

ខ. គ្រប់គ្រងការដ្ឋានផ្លូវថ្នល់ ស្ពាន និងកំពង់ចម្លង :

១. សិក្សា និង រៀបចំកម្មវិធីស្តីពីការថែទាំផ្លូវថ្នល់ និង ស្ពាន :

- រៀបចំថវិកាថែទាំប្រចាំ និង ខួប ។

- ស្រាវជ្រាវទិដ្ឋភាពការខូចខាតផ្លូវថ្នល់ សំណង់សិល្បការ្យនានា លើកវិធីសាស្ត្រការងារថែទាំ និងជួសជុល ។

២. រៀបចំថវិកា បែងចែកមធ្យោបាយតាមដាន និងត្រួតពិនិត្យលើការដ្ឋានសាងសង់ផ្លូវថ្នល់ ស្ពាន :

- រៀបចំថវិកា បែងចែកមធ្យោបាយតាមដាន និងត្រួតពិនិត្យជាប្រចាំ ប្រចាំឆ្នាំ ប្រចាំ៥ឆ្នាំ ចំពោះសំណង់ផ្លូវថ្នល់ ស្ពានសំខាន់ៗ ។

៣. វាយតំលៃការដ្ឋានដែលសំរេចហើយ ។

៤. គ្រប់គ្រងកំពង់ចម្លង សាឡាងរដ្ឋ និង ឯកជន :

- លើកផែនការ នូវសេចក្តីត្រូវការនូវកំពង់ចម្លងថ្មី ឬស្តារ លើកកំរិតឡើងវិញនូវកំពង់ចម្លងចាស់ ។

- លើកផែនការ នូវគំរោងថែទាំគ្រប់គ្រងកំពង់ចម្លង ។

៥. គ្រប់គ្រងរដ្ឋបាល ធនធានមនុស្ស :

- គ្រប់គ្រង ថែរក្សាឯកសារ ។
- បណ្តុះបណ្តាល បំពាក់បំប៉នធនធានមនុស្ស ក្នុង - ក្រៅប្រទេសលើវិស័យបច្ចេកទេស ។
- ក្រុមជំនួយការបច្ចេកទេស និងលេខា ។

គ. ការងារគ្រប់គ្រងមន្ទីរសាធារណការ ខេត្ត- ក្រុង

- ការងារសាធារណការ ។
- ការងារបច្ចេកទេស ។
- ការបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ។

ប្រការ ២ : នាយកដ្ឋានផ្លូវថ្នល់ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ហើយដែលមានមុខងារ និង តួនាទីដូចតទៅ :

ក. ភារកិច្ច និងសិទ្ធិរបស់ប្រធាននាយកដ្ឋាន :

១- ប្រធានមានភារកិច្ច និងសិទ្ធិក្តាប់រួម និងសិទ្ធិសម្រេចរាល់ការងារក្នុងនាយកដ្ឋាន ។

២- ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានណាមួយជាប្រធានស្តីទី នៅពេលដែលខ្លួនអវត្តមាន ។

ខ. ភារកិច្ច និងសិទ្ធិរបស់អនុប្រធាននាយកដ្ឋាន :

១- អនុប្រធានត្រូវអនុវត្តការងារ និងរាយការណ៍ជូនប្រធានអំពីលទ្ធផលការងារទាំងឡាយណា ដែលខ្លួនបានអនុវត្ត ។

២- អនុប្រធានមានភារកិច្ច និងសិទ្ធិ ក្តាប់ការងារផ្ទាល់នូវការិយាល័យ ឬ អង្គភាពជំនាញក្រោមឱវាទ និងសុំសេចក្តីសម្រេចពីប្រធាន ។

នាយកដ្ឋានផ្លូវថ្នល់មានរចនាសម្ព័ន្ធដូចតទៅ :

- ការិយាល័យផែនការ បច្ចេកទេសស្ពានថ្នល់
- ការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ
- ការិយាល័យរដ្ឋបាល បុគ្គលិកធនធានមនុស្ស
- ការិយាល័យសារពើភ័ណ្ឌ និងថែទាំផ្លូវថ្នល់
- ការិយាល័យសុវត្ថិភាពផ្លូវថ្នល់ បរិស្ថាននិងផ្សព្វផ្សាយសាធារណៈ
- ការិយាល័យច្បាប់ និងសាជីវកម្មផ្លូវថ្នល់
- ការិយាល័យទំនាក់ទំនង គ្រប់គ្រងទិន្នន័យ និងសម្ភារៈគ្រឿងចក្រ
- ការិយាល័យគ្រប់គ្រងកំពង់ចម្លងរដ្ឋ និង ឯកជន
- អង្គភាពស្ពាន
- អង្គភាពថ្នល់

ប្រការ ៣ : ការិយាល័យនីមួយៗ ដឹកនាំដោយនាយការិយាល័យមួយរូប និងអមដោយនាយរងការិយាល័យ ជាជំនួយការមួយចំនួនតាមការចាំបាច់ ។

- អង្គភាពស្ពាន និងអង្គភាពផ្ដល់សមមូលនឹងការិយាល័យ ។ អង្គភាពនិមួយៗ ដឹកនាំដោយប្រធាន អង្គភាពមួយរូប និង អមដោយអនុប្រធានអង្គភាពមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ប្រការ ៤ : ការិយាល័យផែនការ បច្ចេកទេសស្ពានថ្នល់ :

ក.ការងារផែនការ

- ប្រមូលផ្ដុំឯកសារ ធ្វើផែនការការងារ ផែនការបច្ចេកទេស តំរូវការគ្រឿងចក្រ សំភារៈ លើកគំរោងចំណាយសំភារៈ គ្រប់គ្រងការងារ រៀបចំជួសជុលគ្រឿងចក្រ និងបរិក្ខាររបស់នាយកដ្ឋាន ។
- គ្រប់គ្រងការងារអនុវត្តន៍របស់អង្គភាពក្រោមឱវាទ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត -ក្រុង និងកែសំរួលផែនការ ។
- រៀបចំគំរោងកម្មវិធីអភិវឌ្ឍន៍ផែនការមេ បណ្ដាញផ្លូវជាតិ ផ្លូវខេត្ត ផ្លូវទីរួមខេត្ត-ក្រុង និងស្ពានវិលេងផ្លូវ ។
- ធ្វើផែនការប្រចាំឆ្នាំ ការងារសាងសង់ ជួសជុល ថែទាំផ្លូវថ្នល់ និងកំពង់ចម្លង ។
- ធ្វើផែនការបៀវត្សមន្ត្រីរាជការ ។
- ធ្វើផែនការ នូវតំរូវការ មន្ត្រីរាជការប្រចាំឆ្នាំ ។
- ធ្វើស្ថិតិនូវផ្លូវថ្នល់ ស្ពាន ក្នុងខេត្ត ក្រុងលើកគំរោងបច្ចេកទេស និងវិធីសាស្ត្រថែទាំជួសជុល រួចបញ្ជូនឯកសារទៅនាយកដ្ឋានផែនការ ។
- សរសេររបាយការណ៍ជាបន្ទាន់ក្នុងករណីចាំបាច់ លើការងារជួសជុល ថែទាំ សាងសង់ផ្លូវថ្នល់ និង សំណង់សិល្បការជូនថ្នាក់ដឹកនាំ ។

ខ. ការងារបច្ចេកទេស :

- រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់នាយកដ្ឋាន និងកំណត់កម្មវិធីអនុវត្តលើគ្រប់ផ្នែកទាំងអស់ ។
- សំរបសំរួលជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្តន៍ ។
- សិក្សាគំរោងដោយអនុវត្តតាមបទដ្ឋាន បច្ចេកទេសរបស់ក្រសួង ។
- ត្រួតពិនិត្យ ណែនាំ និងប្រគល់ទទួលនូវរាល់ការងារផ្លូវថ្នល់ និងសំណង់សិល្បការរបស់អង្គភាពជំនាញក្រោមឱវាទក្រសួង និង បណ្ដាក្រុមហ៊ុនពាក់ព័ន្ធការងារខាងលើបើសិនជាមាន ។
- រៀបចំបទដ្ឋានបច្ចេកទេសប្រពន្ធ័ត្រួតពិនិត្យ និងវាយតំលៃលើការងារថែទាំផ្លូវថ្នល់ ។
- គ្រប់គ្រងបទដ្ឋានកំរិតកំណត់ទម្ងន់យានយន្តគ្រប់ប្រភេទធ្វើចរាចរលើផ្លូវថ្នល់ ។
- ស្រាវជ្រាវទិដ្ឋភាពការខូចខាតផ្លូវថ្នល់ សំណង់សិល្បការនានា លើកវិធីសាស្ត្រការងារថែទាំ និងជួសជុល ។
- គ្រប់គ្រងបទដ្ឋានបច្ចេកទេសក្នុងការងារជំនាញ ។
- ការងារវាស់ស្ទង់ និង ប្លង់លេខា (Topographie)
- ទទួលភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់អោយ ។

ប្រការ ៥ : ការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ :

- លើកគំរោងថវិកានាយកដ្ឋានជូនទៅនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងតាមដានពីការប្រតិបត្តិ ។

- ធ្វើកិច្ចបញ្ជីការ ជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ ។
- រៀបចំពត៌មានអំពីសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- គ្រប់គ្រងរាល់ចំណូល-ចំណាយរបស់នាយកដ្ឋាន ស្របតាមច្បាប់ហិរញ្ញវត្ថុ ។
- គ្រប់គ្រងហិរញ្ញវត្ថុនៃការអនុវត្តន៍របស់អង្គភាពក្រោមឱវាទ និងមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត ក្រុង ។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនថ្នាក់ដឹកនាំតាមឋានានុក្រម ។
- ត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ។
- ត្រួតពិនិត្យលើការវាយតំលៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធិភាពក្នុងការអនុវត្តន៍ ។
- ត្រួតពិនិត្យតាមសំណើពិសេស ។
- ទទួលភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់អោយ ។

ប្រការ ៦ :ការិយាល័យរដ្ឋបាល បុគ្គលិកធនធានមនុស្ស :

ក. ការងាររដ្ឋបាល :

- គ្រប់គ្រងឯកសារ សំណុំលិខិតនានារាល់លិខិតចេញ ចូល ឱ្យបានហ្មឺងម៉ាត់ ។
- ក្រុមជំនួយការបច្ចេកទេស និងលេខា ។
- ចងក្រង និងទុកដាក់ឯកសារតាមលំដាប់ថ្ងៃ ខែ ឆ្នាំ និងតាមប្រភេទនៃឯកសារ ឬ ឱ្យមានសណ្តាប់ធ្នាប់ល្អ ងាយស្រួលក្នុងការថែទាំ និងស្រាវជ្រាវទាន់ពេលវេលា ។
- រៀបចំប្រមូលផ្តុំរាល់ឯកសារដែលមានការពាក់ព័ន្ធដើម្បីធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ របស់នាយកដ្ឋាន ជូនថ្នាក់ដឹកនាំក្រសួងតាមឋានានុក្រម ។

ខ. ការងារបុគ្គលិក-ធនធានមនុស្ស :

- ធ្វើបញ្ជីរាយនាម មន្ត្រីរាជការ ទាំងអស់ដែលមាននៅក្នុងនាយកដ្ឋាន និងសំរង់ស្ថិតិមន្ត្រីរាជការនៅ មន្ទីរ សាធារណការ និងដឹកជញ្ជូនខេត្ត -ក្រុង ។
- រៀបចំបញ្ជីប្រាក់បៀវត្សមន្ត្រីរាជការ ។
- សិក្សាជីវភាពរបស់មន្ត្រីរាជការ និងជួយដល់កិច្ចការនារី ។
- រៀបចំឯកសារជូនប្រធានក្នុងការតែងតាំងឋានៈ ផ្លាស់ប្តូរ តំឡើងឋានន្តរសក្តិ តួនាទី មន្ត្រីរាជការ ។
- រៀបចំរាល់ទំរង់ បែបបទស្តីពីការសរសើរជូនរង្វាន់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ ។
- ធ្វើបញ្ជីវត្តមានគ្រប់ការិយាល័យក្នុងនាយកដ្ឋាន និងកំណត់នូវការងារល្អ របស់មន្ត្រីរាជការ និងក្នុងអង្គភាព ក្រោមឱវាទ ។
- ធ្វើលិខិតបង្គាប់ការ និងបទប្បញ្ញត្តិពិន័យដល់មន្ត្រីរាជការ តាមការសំរេចរបស់ប្រធាន ។
- គ្រប់គ្រង និងបែងចែកឯកសារ សាលាកប័ត្រ តាមឯកទេស និងបច្ចេកទេសជំនាញនិមួយៗ ដើម្បីពិនិត្យ និងសុំយោបល់ពីថ្នាក់ដឹកនាំ ។

- ធានាស្តីពីការអនុវត្តន៏ការ ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងបទបញ្ជាផ្ទៃក្នុងរបស់នាយកដ្ឋាន ។
- លើកសំណើកម្មវិធីបណ្តុះបណ្តាល បំពាក់បំប៉នមុខជំនាញធនធានមនុស្ស ក្នុង និងក្រៅប្រទេស ។
- ត្រូវរៀបចំរាល់សំណុំឯកសារពាក់ព័ន្ធការងារសង្គមកិច្ច ។
- រៀបចំសំណុំឯកសារវាយតំលៃ សន្និដ្ឋានចំពោះមន្ត្រីរាជការដែលបានបញ្ចប់កម្មសិក្សា ។
- ទទួលភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់អោយ ។

ប្រការ ៧ : ការិយាល័យ សារពើភ័ណ្ឌ និងថែទាំផ្លូវថ្នល់ :

- រៀបចំ និងពិនិត្យកែសំរួលជាប្រចាំរៀងរាល់ឆ្នាំ អំពីគោលនយោបាយថែទាំផ្លូវថ្នល់តាមតំរូវការ និង ការខ្វះចន្លោះដើម្បីអោយមានភាពសុក្រឹតធានាគុណភាពដល់ការអនុវត្តន៏ និង ការចំណាយ ។
- រៀបចំ និងគ្រប់គ្រងបរិក្ខារផ្លូវថ្នល់ទ្រព្យសម្បត្តិនាយកដ្ឋាន ហើយត្រូវធ្វើជារៀងរាល់ឆ្នាំ ដើម្បីកែសំរួលនិងបញ្ចូលបន្ថែមទូរលេខថ្មី ១ តាមការចាំបាច់ជាជំនួយសំរាប់ការរៀបចំផែនការដែលមានការពាក់ព័ន្ធតាមការវិវត្តន៏របស់សង្គម ។
- រៀបចំផែនការ និង យុទ្ធសាស្ត្រការងារថែទាំប្រចាំឆ្នាំលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ព្រមទាំងរៀបចំកម្មវិធីចំណាយ កំលាំងពលកម្ម សំភារៈ និងគ្រឿងចក្រ តំរូវការតាមប្រភេទលេខកូដការងារ ។
- ពិនិត្យតាមដានលើរាល់របាយការណ៍ និងការងារប្រតិបត្តិនៃការងារថែទាំផ្លូវថ្នល់ ។
